កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

Implemented by giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

In cooperation with:
ERNST MORITZ ARNDT UNIVERSITÄT GREIFSWALD
Wissen lockt. Seit 1456

ខ្លឹមសារសង្ខេបឯកសារជំនួយសម្រាប់រៀបចំគោលនយោបាយហិរញ្ញប្បទានសុខាភិបាលនៅកម្ពុជា (ឯកសារទី៦)

ឯកសារគោលនយោបាយសង្ខេបនេះមានគោលបំណងគាំទ្រ និងផ្តល់ព័ត៌មានដល់ក្រុមអ្នកសម្រេចចិត្តលើបញ្ហាគន្លឹះមួយចំនួនដែលទាក់ទងទៅនឹងហិរញ្ញប្បទានសុខាភិបាល និងការគាំពារសុខភាពសង្គម។ ឯកសារទាំងនេះមិនមានលក្ខណៈជាឯកសារវិទ្យាសាស្ត្រនោះទេ ប៉ុន្តែជាឯកសារសង្ខេបនូវភស្តុតាង និងគោលគំនិតបច្ចេកទេសនានាដែលក្រុមអ្នកសម្រេចចិត្តអាចពិចារណាយកមកពិភាក្សា។ សេចក្តីសង្ខេបនេះមានជាភាសាខ្មែរ និងភាសាអង់គ្លេស។

# ជំងឺមហារីកមាត់ស្បូននៅកម្ពុជា: តើយើងអាចធ្វើមិនដឹងមិនឮ ដោយមិនដោះស្រាយបញ្ហានេះបានឬទេ?

## សារគន្លឹះ

- ជំងឺមហារីកមាត់ស្បូន ជាជំងឺមហារីកដែលជួបប្រទះញឹកញាប់បំផុតទីពីរក្នុងចំណោមស្ត្រីនៅទូទាំងពិភពលោក និងជាជំងឺមហារីក ដែលធ្ងន់ធ្ងរបំផុតក្នុងចំណោមស្ត្រីនៅក្នុងប្រទេសកម្ពុជា។
- មានការប៉ាន់ប្រមាណថា មានស្ត្រីចំនួន ១០.០០០នាក់ ដែលកំពុងរស់នៅជាមួយជំងឺមហារីកមាត់ស្បូន នៅប្រទេសកម្ពុជាបច្ចុប្បន្ន។ ហើយជារៀងរាល់ឆ្នាំ មានស្ត្រីប្រមាណជា ១.៥០០នាក់ ដែលនឹងវិវត្តទៅជាជំងឺមហារីកមាត់ស្បូន ហើយស្ត្រីប្រមាណ ៨០០នាក់ នឹងស្លាប់ដោយសារជំងឺនេះ។
- ជារៀងរាល់ឆ្នាំ ជំងឺមហារីកមាត់ស្បូនបានសម្លាប់ស្ត្រីស្ទើរតែពាក់កណ្តាល នៃចំនួនមរណភាពដែលទាក់ទងនឹងមាតុភាព
- ជំងឺមហារីកមាត់ស្បូនបង្កឡើងជាចម្បងដោយមេរោគឈ្មោះ Human papilloma Virus (HPV) - ដែលចម្លងតាមការរួមភេទ។
- មានកិច្ចអន្តរាគមន៍បង្ការ និងព្យាបាលដែលមានប្រសិទ្ធភាពតម្លៃ និងមានលទ្ធភាពចំណាយបានសម្រាប់ប្រទេសកម្ពុជា។
- ទោះយ៉ាងណាក្តី ប្រសិទ្ធភាពតម្លៃអាស្រ័យលើគុណភាព និងប្រសិទ្ធផលនៃកិច្ចអន្តរាគមន៍:
  - បច្ចុប្បន្ន ការព្យាបាលនៅមន្ទីរពេទ្យបង្អែកជាតិគឺ មានប្រសិទ្ធផលនៃតម្លៃ ប៉ុន្តែនៅមានចំណុចជាច្រើនដែលត្រូវកែលម្អ។
  - យុទ្ធសាស្ត្រ "រកឃើញ និង ព្យាបាល" ដែលរួមបញ្ចូលគ្នារវាងការស្រាវជ្រាវរកជំងឺមហារីកមាត់ស្បូនរៀងរាល់បីឆ្នាំម្តង នៅលើស្ត្រីទាំងអស់ចន្លោះពី អាយុ ៣០ឆ្នាំ ទៅ ៤៩ឆ្នាំ និងការព្យាបាលដោយគ្រីយ៉ូ (cryotherapy) គឺជាអន្តរាគមន៍ ដែលមានប្រសិទ្ធផលនៃតម្លៃ ដរាបណាការចំណាយសម្រាប់ការស្រាវជ្រាវរកជំងឺមហារីមាត់ស្បូនអាចត្រូវបានរក្សាឱ្យនៅតិចជាង ៥ ដុល្លារអាមេរិក។
  - កម្មវិធីផ្តល់ថ្នាំបង្ការនឹងមានផលប៉ះពាល់លើអត្រានៃជំងឺមហារីកមាត់ស្បូនបន្ទាប់ពី ២៥ឆ្នាំក្រោយមក ហើយនឹងមានប្រសិទ្ធផលនៃតម្លៃ ប្រសិនបើទស្សនៈវិស័យរយៈពេលវែងត្រូវបានពិចារណា។
- ដើម្បីឱ្យថ្នាំបង្ការមានប្រសិទ្ធភាព ស្ត្រីត្រូវការថ្នាំបង្ការប្រឆាំងទល់នឹងមេរោគ HPV ឱ្យបានមុនពេលរួមភេទលើកដំបូង។
- ប្រទេសកម្ពុជា គួរចាប់ផ្តើមអនុវត្តកម្មវិធីស្រាវជ្រាវរកជំងឺមហារីកមាត់ស្បូន និងការព្យាបាលឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដោយមានការបំពេញបន្ថែមពីកម្មវិធីផ្តល់ថ្នាំបង្ការទល់នឹងមេរោគ HPV និងដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍វិស័យសុខាភិបាលរបស់ខ្លួន។ នេះជាអន្តរាគមន៍ទូលំទូលាយដែលនឹងត្រូវចំណាយប្រមាណ ៤លានដុល្លារអាមេរិកក្នុងមួយឆ្នាំ ប៉ុន្តែនឹងអាចបញ្ចៀសមរណភាពប្រមាណ ៧៥០ ក្នុងមួយឆ្នាំ នៅត្រឹមឆ្នាំ២០៣០។
- ការប្រតិបត្តិតាមការស្រាវជ្រាវរកជំងឺមហារីកមាត់ស្បូន និងការព្យាបាលអាចត្រូវបានលើកកម្ពស់តាមរយៈផ្តល់ជំនួយដល់បុគ្គល ឬ ជាយុទ្ធសាស្ត្រ សំរាប់ផលប្រយោជន៍បុគ្គល ដូចជាការប្រើប័ណ្ណសុខភាព (vouchers)។

## សេចក្តីផ្តើម -

## ជំងឺមិនឆ្លង៖ អាទិភាពមួយសម្រាប់កម្ពុជា

ជំងឺមិនឆ្លង (NCD) កំពុងកើនឡើងទាំងនៅលើពិភពលោកនិងនៅកម្ពុជា ដែលមានផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំង លើសង្គមនិងប្រព័ន្ធសុខាភិបាល។ ជំងឺមិនឆ្លងធ្វើឱ្យស្ថានភាពក្រីក្រកាន់តែធ្ងន់ធ្ងរទៅៗ និងបង្កើនការចំណាយយ៉ាងច្រើនលើសេដ្ឋកិច្ចកម្ពុជា។ អង្គការសុខភាពពិភពលោកបានប្រមាណថា ជំងឺមិនឆ្លងដែលធ្ងន់ធ្ងរបំផុតចំនួនបួន(ជំងឺសរសៃឈាមបេះដូង ជំងឺមហារីក ជំងឺផ្លូវដង្ហើមរ៉ាំរ៉ៃ និងជំងឺទឹកនោមផ្អែម) បង្ករអោយមានមរណភាពប្រហែលជា៥០%នៃមរណភាពទាំងអស់នៅកម្ពុជា ហើយតួលេខនេះត្រូវបានព្យាករណ៍ថានឹងកើនឡើងបន្ថែមទៀតដែលជាលទ្ធផលនៃការផ្លាស់ប្តូររបៀបរស់នៅនិងបរិស្ថាន។ ការប្រយុទ្ធនឹងជំងឺមិនឆ្លងតម្រូវឱ្យមានអន្តរាគមន៍ចម្រុះ ដែលរួមបញ្ចូលយុទ្ធសាស្ត្របង្ការ និងការព្យាបាល។ ការអនុវត្តយុទ្ធសាស្ត្រអាស្រ័យនឹងជំងឺដែលជាការខិតខំដ៏ស្មុគស្មាញនិងទាមទារប្រព័ន្ធសុខាភិបាលមួយដែលមានរចនាសម្ព័ន្ធល្អ។

ឯកសារនេះផ្តល់នូវទិដ្ឋភាពទូទៅ នៃបន្ទុកជំងឺមហារីកមាត់ស្បូននៅប្រទេសកម្ពុជា និងសនិទានភាពសម្រាប់សកម្មភាពបង្ការនិងការព្យាបាលទល់នឹងជំងឺនេះ ដោយអំណះអំណាងថា សកម្មភាពបែបនេះអាចមានប្រសិទ្ធផលតម្លៃ និងអាចធ្វើបានទាំងបច្ចេកទេសនិងហិរញ្ញវត្ថុ។

## សនិទានភាព - ហេតុអ្វីទើបត្រូវដោះស្រាយបញ្ហាជំងឺមហារីកមាត់ស្បូន

ជំងឺមហារីកមាត់ស្បូន ឬ cervix uteri carcinoma (CUC) គឺជាដុំមហារីកដ៏សាហាវ ដែលត្រូវបានបង្កឡើងស្ទើរទាំងអស់ដោយការឆ្លងជាប់ជាបន្តនៃវីរុស Human papilloma virus (HPV) - ជាជំងឺកាមរោគ។ ជំងឺមហារីកមាត់ស្បូនជាប្រភេទជំងឺមហារីក ដែលជួបប្រទះញឹកញាប់ជាងគេទីពីរក្នុងចំណោមស្ត្រីទូទាំងពិភពលោកដែលបង្កអោយមានមរណភាពច្រើនជាង ៨៥% នៃមរណភាពដែលបង្ករដោយជំងឺនេះក្នុងប្រទេសដែលមានចំណូលទាប និងមធ្យម។ ជំងឺមហារីកមាត់ស្បូនធ្វើឱ្យមានការចំណាយសង្គម និងសេដ្ឋកិច្ចដ៏សម្បើម ដែលរាំងស្ទះដល់ការអភិវឌ្ឍសេដ្ឋកិច្ច។ ករណីភាគច្រើនត្រូវបានធ្វើរោគវិនិច្ឆ័យរកឃើញលើស្ត្រីនៅអាយុប្រហែល ៥០ឆ្នាំ។ ទោះបីជាមានអត្រាប្រេវ៉ាឡង់ខ្ពស់ក្តីក៏ករណីភាគច្រើននៃជំងឺមហារីកមាត់ស្បូនអាចបង្ការបានដែរ។ នៅក្នុងប្រទេសដែលមានប្រាក់ចំណូលខ្ពស់ កម្មវិធីបង្ការបានរួមចំណែកដល់ការកាត់បន្ថយករណីជាច្រើន និងមរណភាព ដោយការរួមបញ្ចូលការបង្ការបឋម (ការផ្តល់ថ្នាំបង្ការ) និងការបង្ការមធ្យម (ការស្រាវជ្រាវរក និងការយកចេញភ្លាមៗនៃដុំដំបៅក្នុងដំណាក់កាលមុនពេលវិវត្តទៅជាជំងឺមហារីក)។ យុទ្ធសាស្ត្របែបនេះអាចបង្ការបានរហូតដល់ ៨០% នៃជំងឺមហារីកស្បូន។

ប្រហែលជា៣%នៃស្ត្រីពេញវ័យទាំងអស់នៅកម្ពុជាអាចមានដំបៅមាត់ស្បូនក្នុងដំណាក់កាលមុនវិវត្តទៅជាជំងឺមហារីក - របួសតូចនៅមាត់ស្បូន ដែលអាចវិវត្តឈានទៅរកមហារីក បើមិនបានព្យាបាល។ នេះតំណាងឱ្យស្ត្រី ១៦៥.០០០ ដែលស្មើនឹង ១% នៃប្រជាពលរដ្ឋទាំងអស់។ ក្នុងចំណោមស្ត្រីទាំងនេះ មានស្ត្រី ១៥០០នាក់នឹងវិវត្តទៅរកជំងឺមហារីក ហើយ ៨០០នាក់នឹងស្លាប់ជារៀងរាល់ឆ្នាំ បើស្ថានភាពនាពេលបច្ចុប្បន្នមិនត្រូវបានបញ្ចៀសដែលធ្វើឱ្យជំងឺមហារីកមាត់ស្បូនជាជំងឺមហារីកធ្ងន់ធ្ងរបំផុតក្នុងចំណោមស្ត្រីកម្ពុជា។ ជំងឺមហារីកមាត់ស្បូននេះធ្វើឱ្យក្លាយជាបញ្ហាជាតិនៅកម្រិតដូចគ្នានឹងមរណភាពមាតាដែលកំពុងថយចុះជាលំដាប់នៅកម្ពុជា ប៉ុន្តែនៅតែទទួលខុសត្រូវលើមរណភាពមាតា១.៧០០នាក់ រៀងរាល់ឆ្នាំ។

## ការវិភាគ-ដោះស្រាយជំងឺមហារីកមាត់ស្បូនតាមវិធីមានប្រសិទ្ធផលនៃតម្លៃ

### អន្តរាគមន៍ដែលអាចធ្វើបាន

ជំងឺមហារីកមាត់ស្បូន ជាជំងឺមួយដែលត្រូវបានផ្តល់អាទិភាពសម្រាប់ការធ្វើសកម្មភាពរួចទៅហើយ នៅក្នុងផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការប្រយុទ្ធនិងបង្ការជំងឺមិនឆ្លង។ ការបង្ការបឋមតាមរយៈការផ្តល់ថ្នាំបង្ការទល់នឹងមេរោគ HPV ជាវិធីដែលមានប្រសិទ្ធភាពបំផុត ដើម្បីបញ្ចៀសជំងឺមហារីកមាត់ស្បូន ប៉ុន្តែការចំណាយនៃការផ្តល់ថ្នាំបង្ការគួរត្រូវបានប្រៀបធៀបនឹងយុទ្ធសាស្ត្រជំនួសឬបន្ថែមផ្សេងទៀត។ ការផ្តល់ថ្នាំបង្ការអាចមានប្រសិទ្ធផលបំផុត តែក្នុងករណីដែលស្ត្រីបានទទួលថ្នាំបង្ការ មុនពេលរួមភេទលើកដំបូង។ ដូច្នេះយុទ្ធសាស្ត្របង្ការបន្ថែម ដូចជាការពិនិត្យស្រាវជ្រាវរកជំងឺមហារីកមាត់ស្បូន និងការព្យាបាលភ្លាមៗ គឺមានសារៈសំខាន់ ដើម្បីកាត់បន្ថយបន្ទុកនៃជំងឺមហារីកមាត់ស្បូននៅក្នុងរយៈពេលមធ្យម។

មានវិធីពិនិត្យស្រាវជ្រាវរកចំនួនបីដែលត្រូវបានបញ្ជាក់ពីប្រសិទ្ធផល:

- ការពិនិត្យដោយប្រើអាស៊ីតអាសេទីក (VIA) - ជាការពិនិត្យមើលផ្នែកខាងក្រោមនៃស្បូន និងមាត់ស្បូនដោយប្រើអាស៊ីតអាសេទីក ដើម្បីកំណត់រកមើលដំបៅ។
- ប៉ាប់ស្មៀរ (Pap-smear) - ការពិនិត្យមីក្រូទស្សន៍នៃកញ្ចក់ដែលមានគៀសកោសិកាមាត់ស្បូន។
- ការធ្វើតេស្តឌីអិនអេ (DNA) នៃវីរុស HPV - តេស្តឈាមដែលនៅក្នុងនោះមានវត្តមាននៃវីរុស HPV ត្រូវបានបញ្ជាក់ដោយការធ្វើតេស្តរកកូដនៃហ្សែនរបស់ វីរុស HPV។

ការពិនិត្យដោយប្រើអាស៊ីតអាសេទីកមានអត្ថប្រយោជន៍ ដោយវាអាចបញ្ចូលដោយផ្ទាល់តាមយុទ្ធសាស្ត្រ "ពិនិត្យរក និងព្យាបាល" នូវការដកចេញភ្លាមៗ ដំបៅសង្ស័យក្នុងដំណាក់កាលមុនពេលវិវត្តទៅរកជំងឺមហារីក ដោយប្រើការព្យាបាលដោយគ្រីយ៉ូ (cryotherapy) ដែលជាអន្តរាគមន៍សាមញ្ញ។ ក្នុងការព្យាបាលដោយគ្រីយ៉ូ សារជាតិគីមីដែលត្រជាក់ខ្លាំងត្រូវបានប្រើ ដើម្បីបង្កកសម្លាប់ ហើយបន្ទាប់មក យកចេញដំបៅដែលសង្ស័យ។

អវត្តមាននៃការបង្ការ ជំងឺមហារីកមាត់ស្បូនអាចវិវត្ត និងតម្រូវឱ្យមានការព្យាបាលសម្រាប់ជំងឺមហារីករាលដាល ដូចជាការព្យាបាលដោយកាំរស្មី ការព្យាបាលដោយសារធាតុគីមី និងជាញឹកញាប់ដោយវះកាត់យកស្បូនចេញ។ បច្ចុប្បន្ន មានតែមន្ទីរពេទ្យបង្អែកជាតិតែមួយគត់ក្នុងរាជធានីភ្នំពេញ ដែលផ្តល់អន្តរាគមន៍កម្រិតខ្ពស់បែបនេះ។

### ការវិភាគប្រសិទ្ធិផលនៃតម្លៃ

ការជ្រើសរើស និងការបញ្ចូលនូវកិច្ចអន្តរាគមន៍សុខភាពសាធារណៈគួរផ្អែកលើការប្រៀបធៀបរវាង ការចំណាយទៅនឹងប្រសិទ្ធិផលត្រលប់មកវិញ។ ការវាស់វែងដែលគេប្រើជាទូទៅ ដើម្បីវាយតម្លៃប្រសិទ្ធផលនៃការចំណាយ គឺដើម្បីវាស់វែងអំពីតម្លៃនៃការចំណាយលើកិច្ចអន្តរាគមន៏មួយ ឬបណ្តុំនៃកិច្ចអន្តរាគមន៍រួមគ្នា។ វិធីនេះអាចត្រូវបានបង្ហាញតាមរយៈការប្រៀបធៀបការចំណាយលើកិច្ចអន្តរាគមន៏ជាមួយនឹងចំនួនមរណៈដែលត្រូវបានបញ្ចៀស ឬចំនួនឆ្នាំនៃជីវិតដែលអាចរស់បន្តទៀតបាន។ បន្ទាប់មកកិច្ចអន្តរាគមន៏ទាំងនោះត្រូវបានគេយកមកប្រៀបធៀបលើប្រសិទ្ធផលនៃតម្លៃដោយផ្អែកលើអាទិភាពដោយអ្នកធ្វើគោលនយោបាយ។ ដើម្បីវាយតម្លៃថាតើកិច្ចអន្តរាគមន៏មួយណាមានលក្ខណៈប្រសិទ្ធិផលតម្លៃជាង គឺតម្រូវឱ្យមានការកំណត់ចំនុចគោលប្រកបដោយលក្ខណៈច្បាស់លាស់មួយ - គុណតម្លៃមួយដែលជាចំនួនឆ្នាំនៃជីវិតដែលបានសង្គ្រោះដោយកិច្ចអន្តរាគមន៏ ដែលមានចំនួនខ្ពស់សមល្មមដែលនឹងគួរអោយអាជ្ញាធរសាធារណៈយកមកវិនិយោគ។ ការកំណត់ដែលគេប្រើជាទូទៅ គឺជាមធ្យមភាគនៃផលិតផលជាតិសរុបក្នុងស្រុកក្នុងប្រជាពលរដ្ឋម្នាក់ដែលជាតម្លៃប្រជាពលរដ្ឋម្នាក់ៗក្នុងប្រទេសបន្ថែមប្រចាំឆ្នាំ។ កិច្ចអន្តរាគមន៍ត្រូវបានពិចារណាថាមានប្រសិទ្ធផលតម្លៃដរាបណាការចំណាយលើការសង្គ្រោះជីវិត ដែលអាចអោយរស់បានមួយឆ្នាំ គឺតិចជាងអ្វីដែលជីវិតនោះនឹងអាចរួមចំណែក ប្រកបដោយសក្តានុពលទៅសេដ្ឋកិច្ចជាតិរបស់ប្រទេសមួយ។ ការវាយតម្លៃបែបនេះធ្វើឱ្យលេចឡើងនូវការបារម្ភពីក្រមសីលធម៌ និងសង្គមពីភាពសមស្របរបស់វាប៉ុន្តែមិនអាចចៀសវាងបានដោយសារតម្រូវការនៃការសម្រេចចិត្តប្រកបដោយហេតុផលលើការបែងចែកប្រភពធនធាន។

អត្ថប្រយោជន៍មួយទៀតនៃការវិភាគប្រសិទ្ធិផលតម្លៃគឺការវាយតម្លៃលើការសន្មតអំពីតម្លៃ និងការចំណាយជាមធ្យមក្នុងមួយករណី ដែលអាចអោយកំណត់គោលដៅប្រសិទ្ធិភាពតាមរយៈការកំណត់នូវការចំណាយមួយឯកតាក្នុងមួយឆ្នាំនៃជីវិត ដែលត្រូវបានជួយសង្គ្រោះក្នុងកិច្ចអន្តរាគមន៍នីមួយៗ។ នេះមានន័យថា ការសិក្សាបែបនេះអាចជួយកំណត់ការចំណាយខ្ពស់បំផុតដែលប្រព័ន្ធសុខាភិបាលមួយអាចទទួលយកបានមុននឹងកិច្ចអន្តរាគមន៍អស់នូវប្រសិទ្ធផលតម្លៃ។

## ប្រសិទ្ធផលនៃតម្លៃ ការផ្តល់អាទិភាព និងការកំណត់គោលដៅការចំណាយ

ផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការប្រយុទ្ធ និងបង្ការជំងឺមិនឆ្លងបានកំណត់អន្តរាគមន៍អាទិភាព ដើម្បីដោះស្រាយជំងឺមហារីកមាត់ស្បូន។ អនុសាសន៍ទាំងនេះផ្អែកលើភស្តុតាងអន្តរជាតិ។ ជាអកុសល យុទ្ធសាស្ត្រនេះពុំមានការប្រមាណនូវការសិក្សាអំពីតម្លៃ និងខ្វះទិន្នន័យជាក់លាក់ដើម្បីគាំទ្រដល់ការអនុវត្តន៍។ ភស្តុតាងអំពីការសិក្សាអំពីតម្លៃ និងការសិក្សាលក្ខណៈជាគំរូ ដែលនឹងដោះស្រាយព័ត៌មានគម្លាតត្រូវបានបង្ហាញយ៉ាងខ្លីនៅទីនេះ[១]។ ការសិក្សានេះ វាយតម្លៃពីប្រសិទ្ធផលនៃតម្លៃនៃការព្យាបាលជំងឺមហារីករាតត្បាត អភិក្រម "ពិនិត្យរកនិងព្យាបាល" និងការផ្តល់ថ្នាំបង្ការវីរុស HPV នៅក្នុងបរិបទកម្ពុជាក្នុងសំណុំសន្មតហៅថា "សេណារីយ៉ូ"។ វាបង្ហាញផងដែរអំពីការប្រមាណនូវតម្រូវការថវិកាសម្រាប់ការអនុវត្តន៍ទូទាំងប្រទេសនូវសេណារីយ៉ូដែលមានប្រសិទ្ធផលនៃតម្លៃបំផុត។

កថាខណ្ឌបន្ទាប់បង្ហាញពីតួលេខប្រសិទ្ធផលតម្លៃនៃសេណារីយ៉ូអន្តរាគមន៍ឯករាជ្យនិងរួមបញ្ចូលគ្នា។

[១] លទ្ធផលនៃការសិក្សាត្រូវបានបង្ហាញនៅក្នុងឯកសារកំពុងអភិវឌ្ឍឈ្មោះថា "ការប្រមាណតម្លៃនៃជំងឺមហារីកមាត់ស្បូននៅកម្ពុជា៖ ការវិភាគលើផលប៉ះពាល់ថវិកា និងប្រសិទ្ធិភាពតម្លៃ" ដោយ Flessa និង Dietz មាននៅគេហទំព័រ៖ http://giz-cambodia.com/wordpress/wp-content/uploads/Working-Paper-Costing-Cervix-Uteri-Carcinoma.pdf

## ការព្យាបាលជំងឺមហារីកដែលរាតត្បាត

ការវាស់វែងប្រសិទ្ធផលនៃការព្យាបាល ដែលគ្រាន់តែអាចពន្យារអាយុជីវិតរំពឹងទុកដូចក្នុងករណីជំងឺមហារីកនេះគឺជាការលំបាក។ ទោះយ៉ាងណាក្តី អត្រារស់រានត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃប្រសិទ្ធផលនៃការព្យាបាលជំងឺមហារីក។ ទាំងនេះវាស់វែងនូវចំនួនភាគរយនៃអ្នកជំងឺដែលនៅរស់បានប្រាំឆ្នាំ បន្ទាប់ពីការធ្វើរោគវិនិច្ឆ័យ/ការព្យាករណ៍វាសនាអ្នកជំងឺ - ដែលជាធម្មតា ៩០% សម្រាប់ដំណាក់កាលដំបូងនៃជំងឺមហារីកមាត់ស្បូន តែតិចជាង ១០% សម្រាប់ដំណាក់កាលវិវត្តន៍លឿនទៅមុខ។

បច្ចុប្បន្នការព្យាបាលជំងឺមហារីកមាត់ស្បូននៅមន្ទីរពេទ្យបង្អែកជាតិមានតម្លៃប្រហែល ៨០០ដុល្លារអាមេរិកក្នុងអ្នកជំងឺម្នាក់ក្នុងមួយឆ្នាំ។ ការចំណាយទាបនេះដោយសារបច្ចេកវិទ្យាដែលមានស្រាប់ និងតម្លៃកំលាំងពលកម្មទាបនៅកម្ពុជា។ ទោះយ៉ាងណាក្តី ការព្យាបាលជំងឺមហារីកមាត់ស្បូន ដែលមានតម្លៃរហូតដល់ ១៩០០ដុល្លារអាមេរិកក្នុងអ្នកជំងឺម្នាក់ក្នុងមួយឆ្នាំ នៅតែត្រូវបានគេពិចារណាថាមានប្រសិទ្ធផលនៃតម្លៃ ក្នុងករណីដែល ២៥% នៃអ្នកជំងឺបានជាសះស្បើយយ៉ាងមានប្រសិទ្ធភាព។

ការវិនិយោគលើការព្យាបាលដែលមានប្រសិទ្ធភាពមានផលប៉ះពាល់ផងដែរលើការសន្សំការរស់រានរយៈពេលមធ្យម និងរយៈពេលវែង។ ពិធីសារព្យាបាលមួយដែលនឹងពន្យារការរស់រានជីវិតរបស់អ្នកជំងឺ ២ ឆ្នាំទៅ៤ ឆ្នាំ អាចមានតម្លៃរហូតដល់ ៣.៣ លានដុល្លារអាមេរិកនៅឆ្នាំ២០២៥និងនៅតែមានប្រសិទ្ធផលនៃតម្លៃ។ តាមការប្រៀបធៀប ការព្យាបាលដែលមានប្រសិទ្ធភាពដែលអាចព្យាបាលអ្នកជំងឺលើសពី ១០% ជាសះស្បើយនឹងអាចកាត់បន្ថយការចំណាយដោយផ្ទាល់ប្រចាំឆ្នាំសម្រាប់ប្រព័ន្ធសុខាភិបាលបានជាងពាក់កណ្តាល។

## ការពិនិត្យរកនិងព្យាបាល

សកម្មភាពដែលនាំឱ្យមានការចំណាយនាំមុខជាក់ស្តែងនៅក្នុងកិច្ចអន្តរាគមន៍នេះ គឺភាពញឹកញាប់នៃការពិនិត្យស្រាវជ្រាវ ដែលបានស្នើទៅស្ត្រី និងអត្រានៃការប្រតិបត្តិតាមឱវាទរបស់ស្ត្រីដែលមានន័យថាជាអត្រាដែលស្ត្រីត្រូវបានពិនិត្យស្រាវជ្រាវតាមពិធីសារពិនិត្យដោយប្រើអាស៊ីដអាសេទីក ហើយដាលិកាដែលសង្ស័យត្រូវបានយកចេញតាមរយៈការព្យាបាលគ្រីយ៉ូ។

ដោយសន្មត់ថាស្ត្រី ៥០% ប្រតិបត្តិតាមការពិនិត្យស្រាវជ្រាវរក និង ៧៥%ប្រតិបត្តិតាមការព្យាបាលគ្រីយ៉ូ។ការសិក្សាបង្ហាញថា សូម្បីតែការពិនិត្យស្រាវជ្រាវដែលធ្វើរាល់ ៥ ឆ្នាំម្តង សម្រាប់ស្ត្រីទាំងអស់អាយុពី ៣០ឆ្នាំ ទៅ ៦០ឆ្នាំ នៅតែមានប្រសិទ្ធផលនៃតម្លៃហើយចំនួនជាអតិបរមានៃមរណភាពអាចនឹងត្រូវបានបញ្ចៀស។ ការសិក្សានេះ បានផ្តល់អនុសាសន៍ជាបឋមស្នើឱ្យមានការពិនិត្យស្រាវជ្រាវរកតែលើស្ត្រីអាយុពី ៣០ ទៅ ៤៩ឆ្នាំ ដើម្បីកម្រិតតម្រូវការថវិកានៃកម្មវិធីជាតិ។ ការកម្រិតបែបនេះនឹងកាត់បន្ថយការចំណាយនៃកម្មវិធីឱ្យ នៅតិចជាង ៨០០.០០០ដុល្លារអាមេរិកក្នុងមួយឆ្នាំ នៅឆ្នាំ២០២៥ និងមានប្រសិទ្ធផលខ្ពស់នៃតម្លៃ បើសិនការចំណាយក្នុងមួយឯកតាជាមធ្យមសម្រាប់ការពិនិត្យដោយប្រើអាស៊ីដអាសេទីកអាចត្រូវបានរក្សាអោយតិចជាង ៥ ដុល្លារអាមេរិក។

## ការផ្តល់ថ្នាំបង្ការ

ប្រសិទ្ធផលនៃការផ្តល់ថ្នាំបង្ការវីរុស HPV ត្រូវបានធានាប្រសិនបើភាពស៊ាំពេញលេញ (ចាក់ពេញលេញគ្រប់ដូស) អាចសម្រេចបានមុនការប៉ះពាល់ជាដំបូងជាមួយវីរុស HPV - ជាការប្រសើរ នៅពេលក្មេងស្រីមានអាយុពី ៩ ទៅ ១៣ឆ្នាំ។ ដោយពិចារណាពីពេលវេលារវាងអាយុ ដែលមានទំនាក់ទំនងផ្លូវភេទដំបូង និងការធ្វើរោគវិនិច្ឆ័យជំងឺមហារីកមាត់ស្បូន មានន័យថាយុទ្ធនាការផ្តល់ថ្នាំបង្ការនឹងសម្រេចបានផលត្រលប់មកវិញ ជាអតិបរមានៅរយៈ៤០ឆ្នាំក្រោយបន្ទាប់ពីការធ្វើវិនិយោគ។ ដូចគ្នាដែរការប្រតិបត្តិតាមអនុសាសន៍នៃការផ្តល់ថ្នាំបង្ការមិនទំនងជាពេញលេញទេសម្រាប់ថ្នាំបង្ការ ដែលផ្តោតលើក្មេងជំទង់នៅតាមមូលដ្ឋាន ដោយការស្ម័គ្រចិត្ត។ថ្នាំបង្ការវីរុសHPVជាការអភិវឌ្ឍថ្មីដែលប្រសិទ្ធផលនៅមានកម្រិត - ភាពស៊ាំពេញលេញអាចសម្រេចបានតែ ៦៣% នៃស្ត្រីដែលបានទទួលថ្នាំបង្ការ ៣ ដូស ហើយភាពស៊ាំមួយជីវិតពុំទាន់ត្រូវបានផ្ទៀងផ្ទាត់នៅឡើយ។ ថ្នាំបង្ការ វីរុស HPV មានតម្លៃ ២២,៥០ ដុល្លារអាមេរិកក្នុង ១ ដូស និងមានតែនៅគ្លីនិកឯកជនប៉ុណ្ណោះក្នុងតម្លៃប្រហែល ៥០ ដុល្លារអាមេរិក។

ដោយពិចារណានូវឧបសគ្គខាងលើ ការសិក្សាសន្និដ្ឋានថាយុទ្ធនាការផ្តល់ថ្នាំបង្ការវីរុស HPV ទូទាំងប្រទេសនឹងនៅតែមានប្រសិទ្ធផលនៃតម្លៃប្រសិនបើទស្សនវិស័យរយៈពេលវែង( ១០០ឆ្នាំ) ត្រូវបានយកមកពិចារណា។ យុទ្ធនាការផ្តល់ថ្នាំបង្ការវីរុស HPV មួយអាចផ្តួចផ្តើមនៅក្នុងតម្លៃតិចតួចប្រមាណ ២ លានដុល្លារអាមេរិក និងអាចឡើងដល់ ៣ លានដុល្លារអាមេរិកនៅត្រឹមឆ្នាំ២០២៥។

ក្នុងរយៈពេលមធ្យម ការចំណាយនៃការផ្តល់ថ្នាំបង្ការពេញលេញ (គ្រប់ដូស)គួរត្រូវបានពិចារណាកាត់បន្ថយ ដើម្បីធ្វើឱ្យប្រសើរឡើងប្រសិទ្ធផលនៃតម្លៃ។ នេះអាចសម្រេចបានតែនៅក្នុងក្របខ័ណ្ឌនៃចលនាសកល ពីព្រោះមានតែក្រុមហ៊ុនមួយចំនួនតូចដែលផលិតថ្នាំបង្ការ HPV នៅទូទាំងពិភពលោក។ បទពិសោធន៍នៅក្នុងបណ្តាប្រទេសដែលមានចំណូលទាបផ្សេងទៀត បានបង្ហាញថា យុទ្ធនាការនេះអាចត្រូវបានផ្តួចផ្តើមដោយមានការគាំទ្រពីដៃគូ ដូចជា សម្ព័ន្ធពិភពលោក (GAVI) ។ ប៉ុន្តែ សូម្បីបណ្តាប្រទេសមានចំណូលខ្ពស់ភាគច្រើន ក៏នៅខ្វះកម្មវិធីជាតិផ្តល់ថ្នាំបង្ការវីរុស HPV ដែរ។

## កិច្ចអន្តរាគមន៍រួមបញ្ចូលគ្នា

មានតម្រូវការចាំបាច់នូវកម្មវិធី ដែលមានលក្ខណៈទូលំទូលាយមួយដើម្បីដោះស្រាយជំងឺមហារីកមាត់ស្បូន។ ផ្នែកខាងលើបង្ហាញថា សមាសភាគនិមួយៗនៃកម្មវិធីមានប្រសិទ្ធផលនៃតម្លៃតាមវិធីរៀងខ្លួន។ ប៉ុន្តែ ការសិក្សាបានបង្ហាញថាការរួមបញ្ចូលអាចនឹងសម្រេចបានពីកម្មវិធីថ្នាក់ជាតិដែលមានលក្ខណៈទូលំទូលាយ ដែលនឹងរួមបញ្ចូលគ្នានូវការបង្ការបែបវិមជ្ឈការតាមរយៈ "ការពិនិត្យស្រាវជ្រាវរកនិងការព្យាបាល" និងការផ្តល់ថ្នាំបង្ការ ជាមួយនឹងការព្យាបាលជំងឺមហារីកមាត់ស្បូននៅថ្នាក់ជាតិ។ការពិនិត្យស្រាវជ្រាវរកដោយប្រើអាស៊ីដអាសេទីកទំនងជារកឃើញនូវដំណាក់កាលវិវត្តន៍លឿនទៅមុខនៃជំងឺមហារីកមាត់ស្បូន ហើយបើរកឃើញមិនព្យាបាលគឺមិនគោរពតាមក្រមសីលធម៌។

ការសិក្សាបានផ្តល់ជាយោបល់ថា កម្មវិធីដែលមានលក្ខណៈទូលំទូលាយទូទាំងប្រទេស ដែលរួមបញ្ចូលរាល់អន្តរាគមន៍ទាំងអស់គួរត្រូវបានផ្តួចផ្តើមសម្រាប់ការចំណាយក្នុងចំនួនតិចជាង ៤លានដុល្លារអាមេរិកក្នុងមួយឆ្នាំ គឺប្រហែល ០,២៦ដុល្លារអាមេរិកក្នុងស្ត្រីម្នាក់ក្នុងមួយឆ្នាំ។ កម្មវិធីបែបនេះនឹងនៅតែមានប្រសិទ្ធផលនៃតម្លៃដោយសារ ឥទ្ធិពលនៃការរួមបញ្ចូលក្នុងការកាត់បន្ថយមរណភាព និងចំនួនឆ្នាំនៃជីវិតដែលអាចរស់បន្ត បើទស្សនវិស័យសម្រាប់រយៈពេលមធ្យម ២០ឆ្នាំ ត្រូវបានពិចារណា។

ជាបន្ថែមទៅលើកិច្ចអន្តរាគមន៍រួមបញ្ចូល ការអប់រំសុខភាពបន្តពូជសមស្របអាចទប់ស្កាត់បន្ថែមទៀតនូវការឆ្លងរាលដាលនៃជំងឺកាមរោគដូចជាវីរុស HPV ។ យុទ្ធសាស្ត្រផ្តល់ព័ត៌មាន ការអប់រំ និងការប្រាស្រ័យទាក់ទង មិនត្រូវបានប្រមាណតម្លៃជាផ្នែកមួយនៃការសិក្សាទេ តែគួរយ៉ាងហោចណាស់កំណត់គោលដៅការប្រាស្រ័យទាក់ទងដើម្បីផ្លាស់ប្តូរឥរិយាបថសម្រាប់ការកាត់បន្ថយហានិភ័យ ការប្រើប្រាស់ស្រោមអនាម័យ និងការកាត់ស្បែកលឹង្គបុរស (បើសមស្របតាមប្រពៃណីទំនៀមទម្លាប់)។

## សេចក្តីសន្និដ្ឋាន

លទ្ធផលនៃការសិក្សាប្រមាណតម្លៃត្រូវបានសង្ខេបនៅក្នុងឯកសារនេះ បានបញ្ជាក់ពីភាពសមស្របនៃកិច្ចអន្តរាគមន៍ ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធ និងបង្ការជំងឺមិនឆ្លង។ ការសិក្សាបានបញ្ជាក់បន្ថែមពីលទ្ធភាពហិរញ្ញវត្ថុ នៃកម្មវិធីគ្រប់ជ្រុងជ្រោយ ដើម្បីដោះស្រាយបញ្ហាបន្ទាន់ផ្នែកសុខភាពសាធារណៈ។ទោះយ៉ាងណាក្តី ការអនុវត្តកម្មវិធីបែបនេះនឹងតម្រូវឱ្យមានការវិនិយោគមូលធនជាដំបូង ទាំងផ្នែកនយោបាយ និងភ័ស្តុភារ។ ការចំណាយលើការអភិវឌ្ឍសមត្ថភាពនៃកម្មវិធីដែលមានលក្ខណៈទូលំទូលាយ មិនទាន់ត្រូវបានពិចារណានៅឡើយទេ។ ជាភ័ព្វសំណាង ជម្រើសដែលត្រូវបានពិចារណាក្នុងការសិក្សានេះ ភាគច្រើនអាចអនុវត្តបានដោយប្រព័ន្ធសុខាភិបាលសាធារណៈ។ ពិនិត្យដោយប្រើអាស៊ីដអាសេទីក និងការព្យាបាលគ្រីយ៉ូ ត្រូវការការវិនិយោគកម្រិតទាប សម្រាប់ទាំងការអភិវឌ្ឍជំនាញបច្ចេកទេសនិងសំភារៈ។ ប៉ុន្មានឆ្នាំមកនេះ កម្ពុជាបានអភិវឌ្ឍសមត្ថភាពគួរឱ្យកត់សម្គាល់ក្នុងការអនុវត្តកម្មវិធីផ្តល់ថ្នាំបង្ការជំងឺដែលអាចយកទោះប្រើប្រាស់សម្រាប់យុទ្ធនាការផ្តល់ថ្នាំបង្ការវីរុស HPV ។

ការពិចារណាចម្បងមួយទៀតនៃអ្នកបង្កើតគោលនយោបាយគួរតែបង្កើនឡើងជាបន្តនូវតម្លៃក្នុងរយៈពេលវែងដោយសារការមិនបានដោះស្រាយជំងឺមហារីកមាត់ស្បូន។ ការដោះស្រាយករណីដែលមានស្រាប់នឹងអាចចំណាយខ្ពស់ពីព្រោះករណីកើនឡើងជាមួយនឹងកំណើនចំនួនប្រជាពលរដ្ឋ។ ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនិងសង្គមដែលពាក់ព័ន្ធនឹងមានទំហំធំ បើសិនកម្មវិធីកិច្ចអន្តរាគមន៍មិនត្រូវបានផ្តួចផ្តើមអោយបានឆាប់រហ័សទេនោះ។ បច្ចុប្បន្នករណីជំងឺមហារីកមាត់ស្បូនដែលមិនត្រូវបានធ្វើរោគវិនិច្ឆ័យមានចំនួនលើសពី ១០.០០០នាក់។ ក្នុងចំណោមចំនួនទាំងនេះនឹងត្រូវបានគេធ្វើរោគវិនិច្ឆ័យ និងស្រាវជ្រាវរកនៅក្នុងជុំដំបូងនៃកម្មវិធីដែលនឹងផ្តល់លទ្ធផលនូវការកើនឡើងយ៉ាងរហ័សពីដំបូងនូវការចំណាយលើការព្យាបាលនិងដាក់សម្ពាធលើសមត្ថភាពព្យាបាលដែលមានស្រាប់នាពេលបច្ចុប្បន្ន។

ដូច្នេះ ការកែតម្រូវយុទ្ធសាស្ត្រជាបន្តនឹងត្រូវការចាំបាច់ក្នុងការដោះស្រាយជំងឺមហារីកមាត់ស្បូនពិសេសត្រូវមានកិច្ចអន្តរាគមន៍បង្កើតតម្រូវការបន្ថែម ដើម្បីជានាដល់ការស្រូបយកសេវាថ្មី។ កិច្ចអន្តរាគមន៍ស្រដៀងគ្នាដែលបានបង្ហាញអំពីជោគជ័យនៅក្នុងប្រទេសដែលមានចំណូលទាបដទៃទៀតរួមមាន កម្មវិធីប័ណ្ណសុខភាពរួមជាមួយនឹងការកសាងសមត្ថភាពនៃអ្នកផ្តល់សេវាសុខភាព និងការធ្វើទីផ្សារសង្គមនៅថ្នាក់មូលដ្ឋាន។បច្ចុប្បន្នក្រសួងសុខាភិបាលកម្ពុជាកំពុងអនុវត្តកម្មវិធីស្រដៀងគ្នាសម្រាប់សេវាសុខភាពបន្តពូជដែលគាំទ្រដោយកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ ដើម្បីអភិវឌ្ឍន៍។ មេរៀនបទពិសោធន៍ដែលទទួលបានតាមរយៈការអនុវត្តកម្មវិធីនេះនឹងផ្តល់នូវភស្តុតាងប្រកបដោយគុណតម្លៃស្តីអំពីការចំណាយរបស់យុទ្ធសាស្ត្រខាងលើនេះ ក៏ដូចជាយុទ្ធសាស្ត្រមួយដែលមានប្រសិទ្ធភាពបំផុតដើម្បីឱ្យបានទៅដល់ស្ត្រី និងដោះស្រាយបញ្ហាសុខភាពសាធារណៈចម្បង។

**ការទទួលស្គាល់៖** សេចក្តីសង្ខេបនេះផ្អែកលើការស្រាវជ្រាវដោយសាស្ត្រាចារ្យវេជ្ជបណ្ឌិត Steffen Flessa ពីសាកលវិទ្យាល័យ Greifswald ជាមួយការផ្តល់មូលនិធិពីក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ របស់សហព័ន្ធអាឡឺម៉ង់ (BMZ) តាមរយៈគម្រោងការពារសុខភាពសង្គម ដែលអនុវត្តដោយ Deutsche Gesellschaft für Internationale Zusammenarbeit GmbH (GIZ) ។ ពង្រាងដំបូងត្រូវបានរៀបចំដោយបណ្ឌិត Dominik Dietz។ យោបល់លើសេចក្តីព្រាងត្រូវបានផ្តល់ដោយវេជ្ជបណ្ឌិត ជា ម៉េងទៀង ។កំណែចុងក្រោយនេះត្រូវបានកែសម្រួល និងពិនិត្យដោយលោក Adelio Fernandes Antunes និង វេជ្ជបណ្ឌិត Bart Jacobs នៃអង្គការ GIZ ។ សេចក្តីសង្ខេបនេះត្រូវបានត្រួតពិនិត្យជាទូទៅដោយលោក Adelio Fernandes Antunes។ ការកែសម្រួលជាទូទៅនូវការបកប្រែជាភាសារខ្មែរដោយវេជ្ជបណ្ឌិត ជា ម៉េងទៀង និងប្រាក់ សុគន្ធារី។ ជំនួយបច្ចេកទេសសម្រាប់ការបោះពុម្ពផ្សាយឯកសារសង្ខេបនេះដោយ ប្រាក់ សុគន្ធារី ។

| | | | |
|---|---|---|---|
| បោះពុម្ពផ្សាយដោយ | Deutsche Gesellschaft für<br>Internationale Zusammenarbeit (GIZ) GmbH<br>Registered offices Bonn and Eschborn, Germany | សហប្រត្តិបត្តិការជាមួយ | សាកលវិទ្យាល័យ Greifswald |
| | ការិយាល័យបោះពុម្ពផ្សាយ<br><br>ទីក្រុង Bonn and Eschbon ប្រទេសអាល្លឺម៉ង់ | តាងនាមដោយ | ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍន៍របស់សាធារណៈ រដ្ឋសហព័ន្ធអាល្លឺម៉ង់ ( BMZ ) |
| | ៥៣១១៣ ទីក្រុង Bonn ប្រទេសអាល្លឺម៉ង់<br>ទូរស័ព្ទ: +៤៩ ២២៨ ៤៤ ៦០-០<br>ទូរស័ព្ទ: +៤៩ ២២៨ ៤៤ ៦០-១៧ ៦៦ | អ្នកនិពន្ធ | វេជ្ជបណ្ឌិត Steffen Flessa<br>បណ្ឌិត Dominik Dietz |
| | Dag-Hammarskjöld-Weg 1-5<br>៦៥៧៦៥ Eschoborn ប្រទេសអាល្លឺម៉ង់<br>ទូរស័ព្ទ: +៤៩ ៦១ ៩៦ ៧៩-០<br>ទូរស័ព្ទ: +៤៩ ៦១ ៩៦ ៧៩-១១ ១៥<br>អ៊ីម៉ែល: info@giz.de<br>គេហទំព័រ: www.giz.de | បកប្រែដោយ<br><br><br>កែសំរួលដោយ | សាន់សាញ<br><br><br>Bart Jacobs Adelio Fernandes Antunes<br>និង John Paul |
| | ការិយាល័យនៅក្នុងប្រទេសកម្ពុជា | កែសំរួលភាសាខ្មែរ | ជា ម៉េងទៀង<br>ប្រាក់ សុគន្ធារី |
| | គំរោងគាំពារសុខភាពសង្គម<br>ការិយាល័យស្ថិតនៅក្នុងអាគាររបស់វិទ្យាស្ថានជាតិសុខភាពសាធារណៈ<br>ប្រអប់សំបុត្រលេខ ១២៣៨ ទីក្រុងភ្នំពេញ ប្រទេសកម្ពុជា<br>ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៤៧៦<br>ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧៦<br>អ៊ីម៉ែល: giz-kambodscha@giz.de | អ្នករចនាគម្រោងប្លង់<br><br><br>បោះពុម្ព | Invent Cambodia<br><br><br>ខែ សីហា ឆ្នាំ ២០១៥ ប្រទេសកម្ពុជា |